**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

-សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៣៦
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២
-សាលក្រមរដ្ឋប្បវេណីលេខៈ ២៣(អ)
ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ធំ

-បានឃើញច្បាប់ស្ដីពីការរៀបចំអង្គការតុលាការប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤ / ០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

-បានឃើញមាត្រា៧៥ មាត្រា១៨២ និងមាត្រា១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានបើកនិងបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខៈ១៣៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ៖

### ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកំពង់ធំ។

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ។

-សំណុំរឿងរដ្ឋប្បវេណីលេខៈ១៣៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ កំណត់ហេតុស្ដីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី**២៣ ខែវិច្ឆិកា ឆ្នាំ២០២២** ។

រវាងដើមចោទឈ្មោះ [redacted] សុផានី ភេទស្រី អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ឪពុកឈ្មោះ [redacted] សេង (ស្លាប់) ម្ដាយឈ្មោះ [redacted] សុភី (រស់) ប្ដីឈ្មោះ [redacted] ធីរ៉ាវុធ (ស្លាប់) មានកូនចំនួន ៣នាក់ មុខរបរ មេផ្ទះ កម្រិតវប្បធម៌ ថ្នាក់ទី៩ ទោសពីមុន គ្មាន ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

និងចុងចម្លើយឈ្មោះ [redacted] ចន្ធី ភេទប្រុស អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ឪពុកឈ្មោះ [redacted] ធា (រស់) ម្ដាយឈ្មោះ [redacted] ប៉ោះ (រស់) ស្ថានភាពគ្រួសារ នៅលីវ មុខរបរ ពេទ្យវេជ្ជបណ្ឌិតទូទៅ កម្រិតវប្បធម៌ អនុបណ្ឌិត ទោសពីមុន គ្មាន ដោយមានលោក [redacted] លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

### អង្គហេតុ និងចំណុចវិវាទ

**១-ការទាមទារ:**

ក-នៅក្នុងរឿងក្ដីនេះ ដើមចោទប្ដឹងទាមទារសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ធី សងប្រាក់ដើមចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។

២-បង្គាប់ឲ្យចុងចម្លើយសងជម្ងឺចិត្តចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៤-សុំអនុវត្តជាបណ្ដោះអាសន្នលើគ្រប់ចំណុច។

ខ-ចុងចម្លើយធ្វើបណ្ដឹងតបទាមទារ ដែលសុំឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម ៖

១-សុំឲ្យតុលាការច្រានចោលពាក្យបណ្ដឹង ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុផានី ។

២-សុំឲ្យតុលាការសម្រេចបង្គាប់ឲ្យចុងបណ្ដឹងតបឈ្មោះ [redacted] សុផានី សងប្រាក់ចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក មកឲ្យដើមបណ្ដឹងតបឈ្មោះ [redacted] ចន្នី ។

៣-សុំឲ្យតុលាការសម្រេចបង្គាប់ឲ្យចុងបណ្ដឹងតបឈ្មោះ [redacted] សុផានី សងការប្រាក់ដើមចំនួន ៥% ក្នុងមួយឆ្នាំ នៃចំនួនប្រាក់ដើម ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។

៤-សុំឲ្យតុលាការសម្រេចបង្គាប់ឲ្យចុងបណ្ដឹងតបឈ្មោះ [redacted] សុផានី សងថ្លៃសំណងជម្ងឺចិត្ត សោហ៊ុយចំណាយផ្នែកច្បាប់ និងសោហ៊ុយចំណាយផ្សេងៗ មកឲ្យដើមបណ្ដឹងតបឈ្មោះ [redacted] ចន្នី ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។

៥-សុំឲ្យតុលាការប្រកាសអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើមចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។

៦-ប្រាក់ពន្ធលើពាក្យបណ្ដឹង និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងបណ្ដឹងតបឈ្មោះ [redacted] សុផានី ។

**២-ការពន្យល់ត្រួសៗអំពីអង្គហេតុនៃរឿងក្ដី**

កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ ចុងចម្លើយឈ្មោះ [redacted] ចន្នី ភេទប្រុស អាយុ៣៣ឆ្នាំ មុខរបរធ្វើពេទ្យ រស់នៅភូមិ[redacted] បានមកខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] សុផានី ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីយកទៅទិញអេកូដាក់នៅក្លីនិចព្យាបាលជម្ងឺរបស់គាត់ ដោយខ្លួនយល់ថាគាត់ជាកូនប្រសារ ហើយគាត់ត្រូវការលុយ ដើម្បីរកស៊ី ដោយមានការលួងលោម បញ្ចុះបញ្ចូល និងអង្វរកខ្លួនផងនោះ ខ្លួនក៏ជឿទុកចិត្ត ហើយបានយល់ព្រមឲ្យខ្ចីលុយចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដោយផ្ញើទៅធនាគារអេប៊ីអេលេខ: ០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្នី នៅវេលាម៉ោង ១០ និង ១៧ នាទី នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ដោយមិនបានធ្វើកិច្ចសន្យានោះទេ។ រហូតដល់អំឡុងខែធ្នូ ឆ្នាំ២០២១ ឈ្មោះ [redacted] ចន្នី បានព្យាយាមខ្ចីប្រាក់ពីដើមចោទចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីយកទៅសងគ្រឿងសំណង់គេ។ លុះដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៨ និង ១៥ នាទី ដើមចោទក៏បានផ្ញើប្រាក់ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក ទៀតឲ្យទៅឈ្មោះ [redacted] ចន្នី ដោយផ្ញើតាមគណនីធនាគារលេខអេប៊ីអេលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្នី ដដែល ដូច្នេះទឹកប្រាក់សរុបចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ក្រោយមកនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០២២ ដើមចោទបានទៅទារប្រាក់ពីចុងចម្លើយឈ្មោះ [redacted] ចន្នី វិញ ស្រាប់ចុងចម្លើយឆ្លើយថា អត់សងទេ ដូច្នេះ ដើម្បីការពារផលប្រយោជន៍តាមផ្លូវច្បាប់ ទើបខ្លួនដាក់ពាក្យបណ្ដឹងមកសាលាដំបូងខេត្តកំពង់ធំតែម្ដង៕

**៣.សេចក្ដីថ្លែងការណ៍របស់គាគីនាពេលទាញហេតុផលផ្ទាល់មាត់**

ដើមចោទឈ្មោះ [redacted] សុផានី បានធ្វើសេចក្ដីថ្លែងការណ៍ថា: នាងខ្ញុំសុំទាមទារឲ្យតុលាការចេញសាលក្រមដូចខាងក្រោម:

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ចន្នី សងប្រាក់ដើមចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។

២-បង្គាប់ឲ្យចុងចម្លើយសងជម្ងឺចិត្តចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៤-សុំអនុវត្តជាបណ្តោះអាសន្នលើគ្រប់ចំណុច។

កាលពីនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ចុងចម្លើយបានសុំខ្ចីប្រាក់ ហើយនាងខ្ញុំបានបាញ់តាមកុងABA របស់ខ្ញុំទៅ កុងABA របស់ឈ្មោះ [redacted] ចន្ធី ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក តាមរយៈលេខកូដ:៥៧៩៥៨៧៦៧៣១ និងនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ នាងខ្ញុំបានបាញ់តាមកុងABA របស់ខ្ញុំទៅ កុងABAរបស់ឈ្មោះ [redacted] ចន្ធី ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក តាមរយៈលេខកូដ:៧៧៨៩៤៩៥៥៦៥ ដូច្នេះសរុបទាំងអស់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ការខ្ចីលុយលើកដំបូង គឺដើម្បីទៅទិញម៉ាស៊ីនអេកូ និងខ្ចីលើកទី២ គឺទៅខ្ចីពង្រីកក្លីនិករបស់ចុងចម្លើយបន្ថែមនៅឯស្រុកតាំងគោក ។

-ចុងចម្លើយឈ្មោះ [redacted] ចន្ធី បានធ្វើសេចក្តីថ្លែងការណ៍តបថា: ចំពោះលុយចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ខ្ញុំបាទពិតជាបានទទួលពីឈ្មោះ [redacted] សុផានី ពិតប្រាកដមែន ប៉ុន្តែជាថ្លៃទូទាត់សងថ្លៃបណ្តាការ ដោយបាញ់តាមកុងABA ដោយមូលហេតុកន្លងមក ខ្ញុំបាទបានភ្ជាប់ពាក្យជាមួយកូនគាត់ឈ្មោះ [redacted] វ៉ាន់លីហ្សា ដោយខ្ញុំបាទឱ្យថ្លៃបណ្តាការ ចំនួន ៣៣០០០ (បីម៉ឺនបីពាន់) ដុល្លារអាមេរិក ជាប្រាក់សុទ្ធប្រគល់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ ដូចមានភ្ជាប់ជូននៅក្នុងវីដេអូ និងកងដៃពេជ្រតម្លៃ ៥៨០០ (ប្រាំពាន់ប្រាំបីរយ) ដុល្លារអាមេរិក និងជញ្ជៀនពេជ្រតម្លៃ ១២០០ (មួយពាន់ពីររយ) ដុល្លារអាមេរិក រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១ ខ្ញុំបាទ និងឈ្មោះ [redacted] វ៉ាន់លីហ្សា សែនព្រេងតាមប្រពៃណី ប៉ុន្តែឈ្មោះ [redacted] វ៉ាន់លីហ្សា មិនព្រមផ្សំដំណេកជាមួយខ្ញុំបាទ នោះទេ ហើយបានសារភាពថានៅចំពោះមុខខ្ញុំ និងចំពោះមុខ [redacted] សុផានី និង [redacted] សុផាណា គាត់មិនដែលស្រឡាញ់ខ្ញុំនោះទេ កន្លងមក គឺម្តាយរបស់ខ្ញុំជាអ្នកឆ្លើយឆ្លងសារ។ ក្រោយពីដឹងរឿងនេះហើយ ធ្វើអោយពួកយើងមិនចុះសម្រុងគ្នា តែក្រោយមកឈ្មោះ [redacted] សុផានី បាននិយាយថាមិនអីទេ ហើយខ្ញុំបាទបានទាមទារថ្លៃបណ្តាការការវិញ។ ក្រោយពីចរចារគ្នាត្រូវឈ្មោះ [redacted] សុផានី បានប្រគល់ចំនួន ២លើក ដោយមានទឹកប្រាក់សរុប ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាថ្លៃទូទាត់សងថ្លៃបណ្តាការ ។ ការព្រមព្រៀងប្រគល់ប្រាក់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក នេះគឺតាមឆាតតេឡេក្រាម ដោយខ្ញុំបាននិយាយថា៖ ស្អែកខ្ញុំយកលុយអោយម៉ាក់ ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ហើយកាត់ឡានឱ្យខ្ញុំមក បើមិនចង់អោយឡានខ្ញុំ ម៉ាក់ឱ្យខ្ញុំ ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកក៏បាន ហើយយកឡាននឹងទៅទៅ ហើយម៉ាក់នៅតែជាម៉ាក់របស់ខ្ញុំជារហូត អូខេ ពេលនោះគាត់ឆ្លើយថា ចឹងក៏បាន ម៉ាក់ក៏ហត់ដែរ ។ ក្រោយមកនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ ឈ្មោះ [redacted] សុផានី បានបាញ់លុយឱ្យខ្ញុំចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក បង្គ្រប់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។

មុនពេលភ្ជាប់ពាក្យឈ្មោះ [redacted] សុផានី បានលួងលោមខ្ញុំបាទឱ្យផ្ញើប្រាក់ចំនួន ១៩០០០ (មួយម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ជាថ្លៃកក់ប្រាក់ទិញដីឱ្យខ្ញុំបាទ ដោយប្រតិបត្តិការគណនេយ្យធនាគារABA របស់ឈ្មោះ [redacted] ធីរ៉ាវុធ ត្រូវជាប្តីរបស់ឈ្មោះ [redacted] សុផានី តាមរយៈលេខ:០៨៥៣៨៩០០០ ចេញពីគណនេយ្យរបស់ខ្ញុំបាទលេខ:០៩០៨៩០៨២៨ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០។ ក្រោយពេលខ្ញុំបាទភ្ជាប់ពាក្យជាមួយកូនគាត់ឈ្មោះ [redacted] វ៉ាន់លីហ្សា រួចហើយ ឈ្មោះ [redacted] សុផានី បានលួងលោមឱ្យសន្សំប្រាក់របស់ខ្ញុំបាទទុកនៅហ្វ៉ឹងកុងរបស់ឈ្មោះ [redacted] សុផានី ជាបន្តបន្ទាប់ដែលមានទឹកប្រាក់ចំនួន ១០៥០០ (មួយម៉ឺនប្រាំរយ) ដុល្លារអាមេរិក ហើយផ្ញើចូលទៅក្នុងគណនេយ្យរបស់ឈ្មោះ [redacted] ធីរ៉ាវុធ ជា

ប្តីរបស់ឈ្មោះ [redacted] សុផានី និងគណនេយ្យរបស់ឈ្មោះ [redacted] សុផានី ហើយការផ្ញើប្រាក់សន្សំទុកនេះមានចំនួន ៨ លើក។

-លើកទី១ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ផ្ទេរចេញពីគណនេយ្យលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី២ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៣ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៤ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៥ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៦ ចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០០២៦៩៦៦៧១ របស់ឈ្មោះ [redacted] សុផានី ។

-លើកទី៧ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០០២៦៩៦៦៧១ របស់ឈ្មោះ [redacted] សុផានី ។

-លើកទី៨ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

ក្រោយមកពីឈ្មោះ [redacted] សុផានី បានប្រាក់ទាំងនេះសរុបទាំងអស់ចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនប្រាំរយ) ដុល្លារអាមេរិក ហើយឈ្មោះ [redacted] សុផានី រកលេស ម្តងថ្ងៃនេះ ម្តងថ្ងៃនោះ និងមិនបានប្រគល់ប្រាក់ទាំងអស់នោះមកឱ្យខ្ញុំបាទវិញនោះទេ។ ដូច្នេះខ្ញុំបាទស្នើសុំតុលាការចេញសាលក្រមដែលបណ្តឹងតបទាមទារដូចខាងក្រោម៖

១-សុំឱ្យតុលាការច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុផានី ។

២-សុំឱ្យតុលាការសម្រេចបង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ [redacted] សុផានី សងប្រាក់ចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក មកឱ្យដើមបណ្តឹងតបឈ្មោះ [redacted] ចន្ទី ។

៣-សុំឱ្យតុលាការសម្រេចបង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ [redacted] សុផានី សងការប្រាក់ដើមចំនួន ៥% ក្នុងមួយឆ្នាំ នៃចំនួនប្រាក់ដើម ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។

៤-សុំឱ្យតុលាការសម្រេចបង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ [redacted] សុផានី សងថ្លៃសំណងជម្ងឺចិត្ត សោហ៊ុយចំណាយផ្នែកច្បាប់ និងសោហ៊ុយចំណាយផ្សេងៗ មកឱ្យដើមបណ្តឹងតបឈ្មោះ [redacted] ចន្ទី ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។

៥-សុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។



Scanned with CamScanner

៦-ប្រាក់ពន្ធលើពាក្យបណ្តឹង និងប្រាក់ប្រឆាំងក្តីជាបន្ទុករបស់ចុងបណ្តឹងតបឈ្មោះ [redacted] សុផានី ។

-លោក [redacted] ម៉េងហោ បានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្ញុំបាទសុំរក្សាការទាមទារដូចពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] សុផានី ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ និង សុំច្រានចោលចំពោះបណ្តឹងតប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ ទាំងស្រុង ដោយសារកូនក្តីរបស់ខ្ញុំបានទទួលប្រាក់សរុបតែ ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ជាថ្លៃបណ្ណាការ ដែលចុងចម្លើយបង់រំលស់ ដោយវេរលុយតាមគុងធនាគារម្តង ១០០០ (មួយពាន់) ដុល្លារអាមេរិក និងម្តង ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក សរុបបាន ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក តាមរយៈធនាគារចំនួន ២៧៥០០ (ពីរម៉ឺនប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក និងឱ្យផ្ទាល់ចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក ហើយលុយនឹងត្រូវបានយកទៅរៀបចំភ្ជាប់ពាក្យនៅភ្នំពេញ និងរៀបអាពាហ៍ពិពាហ៍នៅខេត្តកំពង់ធំ បានចំណាយទៅលើពិធីនេះទាំងអស់។ ក្រោយមក នៅពេលប្តីរបស់កូនក្តីខ្ញុំស្លាប់ទើបមានបញ្ហា រកាំរកុស រវាងឈ្មោះ [redacted] ចន្ធី និងកូនខ្ញុំ ។ ក្នុងនាមកូនក្តីរបស់ខ្ញុំជាម្តាយបានទៅសម្របសម្រួលប្តីប្រពន្ធឱ្យត្រូវគ្នា ប៉ុន្តែមិនត្រូវគ្នានោះទេ បន្ទាប់មកឈ្មោះ [redacted] ចន្ធី បានខ្ចីលុយចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីទិញម៉ាស៊ីនអេកូ ប្រសិនបើពេលនោះចុងចម្លើយ សុំលុយបណ្ណាការ ក៏កូនក្តីខ្ញុំមិនឱ្យនោះដែរ ព្រោះលុយបណ្ណាការបានចាត់ចែង ពិធីភ្ជាប់ពាក្យ និងពិធីរៀបអាពាហ៍ពិពាហ៍អស់ហើយ។ ការលើកឡើងថា ចុងចម្លើយបានយកលុយពី ដើមចោទចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាថ្លៃបណ្ណាការ គឺមិនត្រឹមត្រូវនោះទេ ព្រោះលុយនេះគឺជាលុយខ្ចី ដោយគាត់សន្យាសងវិញ ក្នុងមួយខែ ១០០០ (មួយពាន់) ដុល្លារអាមេរិក ទើបកូនក្តីខ្ញុំយល់ព្រមឱ្យ ហើយពេលនោះចុងចម្លើយបាននិយាយថាខ្លួន និងសងប្រាក់អោយមកកូនក្តីឱ្យគ្រប់បើទោះបីជាខ្លួនមិនត្រូវជាមួយប្រពន្ធក៏ដោយ សុំឱ្យតុលាការពិចារណាទៅលើពេលវេលា នៃការបង់លុយបណ្ណាការ និងការខ្ចីលុយ ។

## ចំណុចវិវាទ

១-ដើមចោទថាប្រាក់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាការខ្ចីប្រាក់ ប៉ុន្តែចុងចម្លើយថាប្រាក់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាថ្លៃបណ្ណាការ ។

២-ចុងចម្លើយថា ដើមចោទជំពាក់ប្រាក់ចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនប្រាំរយ) ដុល្លារអាមេរិក ជាថ្លៃកក់ដីនិងថ្លៃសឡូក្រោយភ្ជាប់ពាក្យ ដើមចោទបដិសេធមិនទទួលស្គាល់នោះទេ ប៉ុន្តែទទួលស្គាល់ថាជាថ្លៃបណ្ណាការ។

-ក្រោយពីបានឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

-ក្រោយពីបានពិនិត្យភស្តុតាងជាសហមូហវិធីនាពេលទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ ។

## សាលាដំបូងខេត្តកំពង់ធំ

## សំអាងហេតុ

១-យល់ឃើញថា: ពាក្យបណ្តឹងចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] សុផានី មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងតាមគតិច្បាប់ គប្បីតុលាការ ទទួលមកពិនិត្យ និងសម្រេចតាមផ្លូវច្បាប់។



Scanned with CamScanner

២-យល់ឃើញថា: ដើមចោទឈ្មោះ [redacted] សុផានី បានធ្វើសេចក្តីថ្លែងការណ៍ថា: កាលពីនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ចុងចម្លើយបានសុំខ្ចីប្រាក់ ហើយខ្លួនបានបាញ់តាមកុងABA របស់ខ្លួនទៅ កុងABA របស់ឈ្មោះ [redacted] ចន្នី ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក តាមរយៈលេខកូដ:៥៧៩៥៨៧៦៧៣១ និងនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ ខ្លួនបានបាញ់តាមកុងABA របស់ខ្លួនទៅ កុងABAរបស់ឈ្មោះ [redacted] ចន្នី ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក តាមរយៈលេខកូដ:៧៧៨៩៤៩៥៥៦៥ ដូច្នេះសរុបទាំងអស់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ការខ្ចីលុយលើកដំបូង គឺដើម្បីទៅទិញម៉ាស៊ីនអេកូ និងខ្ចីលើកទី២ គឺទៅខ្ចីពង្រីកក្លីនិករបស់ចុងចម្លើយបន្ថែមនៅឯស្រុកតាំងគោក ។

៣-យល់ឃើញថា:ចុងចម្លើយឈ្មោះ [redacted] ចន្នី បានធ្វើសេចក្តីថ្លែងការណ៍តបថា: ចំពោះលុយចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ខ្លួនពិតជាបានទទួលពីឈ្មោះ [redacted] សុផានី ពិតប្រាកដមែន ប៉ុន្តែជាថ្លៃទូទាត់សងថ្លៃបណ្តាការ ដោយបាញ់តាមកុងABA ដោយមូលហេតុកន្លងមក ខ្លួនបានភ្ជាប់ពាក្យជាមួយកូនគាត់ឈ្មោះ [redacted] វ៉ាន់លីហ្សា ដោយរូបខ្លួនឱ្យថ្លៃបណ្តាការ ចំនួន ៣៣០០០ (បីម៉ឺនបីពាន់) ដុល្លារអាមេរិក ជាប្រាក់សុទ្ធប្រគល់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ ដូចមានភ្ជាប់ជូននៅក្នុងវីដេអូ និងកងដៃពេជ្រតម្លៃ ៥៨០០ (ប្រាំពាន់ប្រាំបីរយ) ដុល្លារអាមេរិក និងជញ្ជៀនពេជ្រតម្លៃ ១២០០ (មួយពាន់ពីររយ) ដុល្លារអាមេរិក រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១ រូបខ្លួន និងឈ្មោះ [redacted] វ៉ាន់លីហ្សា សែនព្រេងតាមប្រពៃណី ប៉ុន្តែឈ្មោះ [redacted] វ៉ាន់លីហ្សា មិនព្រមផ្សំដំណេកជាមួយរូបខ្លួន នោះទេ ហើយបានសារភាពថានៅចំពោះមុខខ្លួន និងចំពោះមុខ [redacted] សុផានី និង [redacted] សុផាណា គាត់មិនដែលស្រឡាញ់ខ្លួននោះទេ កន្លងមក គឺម្តាយរបស់ខ្លួនជាអ្នកឆ្លើយឆ្លងសារ។ ក្រោយពីដឹងរឿងនេះហើយ ធ្វើអោយពួកយើងមិនចុះសម្រុងគ្នា តែក្រោយមកឈ្មោះ [redacted] សុផានី បាននិយាយថាមិនអីទេ ហើយខ្លួនបានទាមទារថ្លៃបណ្តារការវិញ។ ក្រោយពីចរចារគ្នាត្រូវឈ្មោះ [redacted] សុផានី បានប្រគល់ចំនួន ២លើក ដោយមានទឹកប្រាក់សរុប ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាថ្លៃទូទាត់សងថ្លៃ  បណ្តាការ ។ ការព្រមព្រៀងប្រគល់ប្រាក់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក នេះគឺតាមឆាតតេឡេក្រាម ដោយខ្លួនបាននិយាយថា៖ ស្អែកខ្លួនយកលុយអោយម៉ាក ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ហើយកាត់ឡានឱ្យខ្លួនមក បើមិនចង់អោយឡានខ្លួន ម៉ាក់ឱ្យខ្លួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកក៏បាន ហើយយកឡាននឹងទៅទៅ ហើយម៉ាក់នៅតែជាម៉ាក់របស់ខ្លួនជារហូត អូខេ ពេលនោះគាត់ឆ្លើយថា ចឹងក៏បាន ម៉ាក់ក៏ហត់ដែរ ។ ក្រោយមកនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ ឈ្មោះ [redacted] សុផានី បានបាញ់លុយឱ្យខ្លួនចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក បង្គ្រប់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។

មុនពេលភ្ជាប់ពាក្យឈ្មោះ [redacted] សុផានី បានលួងលោមខ្លួនឱ្យផ្ញើប្រាក់ចំនួន ១៩០០០ (មួយម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ជាថ្លៃកក់ប្រាក់ទិញដីឱ្យខ្លួន ដោយប្រតិបត្តិការគណនេយ្យធនាគារABA របស់ឈ្មោះ [redacted] ធីរ៉ាវុធ ត្រូវជាប្តីរបស់ឈ្មោះ [redacted] សុផានី តាមរយៈលេខ:០៨៥៣៨៤០០០ ចេញពីគណនេយ្យរបស់ខ្លួនលេខ:០៨១៨៨០៨២៨ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០។ ក្រោយពេលខ្លួនភ្ជាប់ពាក្យជាមួយកូនគាត់ឈ្មោះ [redacted] វ៉ាន់លីហ្សា រួចហើយ ឈ្មោះ [redacted] សុផានី បានលួងលោមឱ្យសន្សំប្រាក់របស់ខ្លួនទុកនៅហ្វ៊ីងកុងរបស់ឈ្មោះ [redacted] សុផានី ជាបន្តបន្ទាប់ដែលមានទឹកប្រាក់ចំនួន ១០៥០០ (មួយម៉ឺនប្រាំរយ) ដុល្លារអាមេរិក ហើយផ្ញើចូលទៅក្នុងគណនេយ្យរបស់ឈ្មោះ [redacted] ធីរ៉ាវុធ ជាប្តីរបស់ឈ្មោះ [redacted] សុផានី និងគណនេយ្យរបស់ឈ្មោះ [redacted] សុផានី ហើយការផ្ញើប្រាក់សន្សំទុកនេះមានចំនួន ៨ លើក៖

-លើកទី១ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ផ្ទេរចេញពីគណនេយ្យលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី២ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៣ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៤ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៥ ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

-លើកទី៦ ចំនួន ២០០០ (ពីរពាន់) ដុល្លារអាមេរិក នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០០២៦៩៦៦៧១ របស់ឈ្មោះ [redacted] សុផានី ។

-លើកទី៧ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០០២៦៩៦៦៧១ របស់ឈ្មោះ [redacted] សុផានី ។

-លើកទី៨ ចំនួន ១៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ផ្ទេរចេញពីគណនីលេខ:០៨១៨៨០៨២៨ របស់ឈ្មោះ [redacted] ចន្ទី ទៅគណនីលេខ:០៨៥៣៨៤០០០ របស់ឈ្មោះ [redacted] ធីរ៉ាវុធ ។

ក្រោយមកពីឈ្មោះ [redacted] សុផានី បានប្រាក់ទាំងនេះសរុបទាំងអស់ចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនប្រាំរយ) ដុល្លារអាមេរិក ហើយឈ្មោះ [redacted] សុផានី រកលេស ម្តងថ្ងៃនេះ ម្តងថ្ងៃនោះ និងមិនបានប្រគល់ប្រាក់ទាំងអស់នោះមកឲ្យខ្លួនវិញនោះទេ ។

**៤-យល់ឃើញថា:** តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយ និងភស្តុតាងប្រមូលបានឃើញថា: ចុងចម្លើយទទួលស្គាល់ថាពិតបានជាទទួលប្រាក់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ពីឈ្មោះ [redacted] សុផានី ពិតប្រាកដមែន ប៉ុន្តែជាលុយថ្លៃបុណ្ណាការប៉ុណ្ណោះ មិនមែនជាលុយខ្ចីប្រាក់នោះទេ ប៉ុន្តែចុងចម្លើយពុំមានភស្តុតាងណាមកបញ្ជាក់ថា ជាថ្លៃប៉ុណ្ណាការនោះទេ ការអះអាងលុយបណ្ណាការក៏ពុំមានមូលហេតុត្រូវសងដែរ ជាប្រាក់ចាយវាយពេលមង្គលការប៉ុណ្ណោះ ពុំអាចប្តឹងទាមទារបានឡើយ ។ ចំណែកឯ ដើមចោទបានបាញ់លុយតាមកុងABA ចំនួន ២ លើក លើកទី១ ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក តាមរយៈលេខកូដប្រតិបត្តិការ:៥៧៩៥៨៧៦៧៣១ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ និងលើកទី២ ចំនួន ១០០០០ (មួយម៉ឺន) ដុល្លារអាមេរិក តាមរយៈលេខកូដប្រតិបត្តិការ:៧៧៨៩៤៩៥៥៦៥ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ ពិតប្រាកដមែន ជាការទិញម៉ាស៊ីនអេកូ និងពង្រីកគ្លីនិក ជាការសមរម្យ គួរឲ្យជឿបាន ដូច្នេះគប្បីតុលាការទទួលស្គាល់ថាពិតជាមានអង្គហេតុកិច្ចសន្យាខ្ចីប្រាក់ពិតប្រាកដមែន។

**៥-យល់ឃើញថា:** ពាក្យបណ្តឹងតប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ របស់ដើមបណ្តឹងតបឈ្មោះ [redacted] ចន្ទី គឺអង្គហេតុមួយដោយឡែក ដោយដើមបណ្តឹងតប បានទាមទារប្រាក់ចំនួន ២៩៥០០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ជាប្រាក់ថ្លៃដី និងថ្លៃសន្សំក្រោយភ្ជាប់ពាក្យនោះពុំសមហេតុផលឡើយ ខ្លួនក៏អាចសន្សំខ្លួនឯងបាន ខ្លួន

ក៏អាចទិញខ្លួនឯងបានពុំចាំបាច់ផ្ញើប្រាក់គេទុកទិញដីនោះទេ  តុលាការពុំអាចជឿបានឡើយ  ដូច្នេះគប្បីតុលាការច្រានបណ្តឹងតបចោលទាំងមូល តាមមាត្រា៨៦ កថាខណ្ឌទី២ និងមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៦-យល់ឃើញថា:** ដើមបណ្តឹងទាមទារឱ្យចុងចម្លើយសងថ្លៃខាតបង់ពេលវេលា ថ្លៃសេវាមេធាវី និងចំណាយផ្សេងៗចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក គប្បីតុលាការឱ្យសង ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដែលវាសមនឹងព្យសនកម្មដែលបានកើតឡើង។

**៧-យល់ឃើញថា:** ដើមចោទប្តឹងសុំឱ្យតុលាការប្រកាសអនុវត្តសាលក្រមជាបណ្តោះគ្រប់ចំណុច តុលាការយល់ឃើញថា ការស្នើសុំនេះ ពុំមានភាពចាំបាច់ឡើយ គប្បីតុលាការច្រានចោលការទាមនេះ ។

**៨-យល់ឃើញថា:** ដើមចោទសុំឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីមានលក្ខណៈសមស្របតាមច្បាប់ដោយចុងចម្លើយជាអ្នកមានកំហុស មិនគោរពកាតព្វកិច្ចនៃកិច្ចសន្យា គប្បីឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **ចន្ទី** សងប្រាក់ដើម ឱ្យទៅដើមចោទ ឈ្មោះ [redacted] **សុផានី** ចំនួន **២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក** ។

២-ច្រានចោលបណ្តឹងតបរបស់ឈ្មោះ [redacted] ចន្ទី ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ។

៣-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **ចន្ទី** សងការខាតបង់ពេលវេលា ថ្លៃសេវាមេធាវី និងចំណាយផ្សេងៗចំនួន ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅដើមចោទ ឈ្មោះ [redacted] **សុផានី** ។

៤-ការទាមទារលើសពីនេះ ច្រានចោល ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៦-សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] **សុផានី** និងចុងចម្លើយឈ្មោះ [redacted] **ចន្ទី** ព្រមទាំងមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី**២៧** ខែធ្នូ ឆ្នាំ**២០២២** ។

ទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃដែលភាគីបានទទួលនូវអនុសារសាលក្រមនេះ។

ថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅកំពង់ធំ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

..............................................................................................................................................

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅកំពង់ធំ,ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner